សេចក្តីជូនដំណឹងស្តីពីសិទ្ធិកាន់កាប់ជាកម្មសិទ្ធិដែល
ស្ថិតក្រោមច្បាប់ស្តីពីអំពើហិង្សាប្រឆាំងនឹងស្ត្រី

ក្រសួងអភិវឌ្ឍន៍លំនៅដ្ឋាន និងទីក្រុងសហរដ្ឋអាមេរិក
(U.S. Department of Housing and Urban Development)
OMB អនុម័តលេខ No. 2577-0286
ផុតកំណត់នៅថ្ងៃទី 30/06/2017

**[បញ្ចូលឈ្មោះក្រុមហ៊ុនផ្តល់សេវាកម្មលំនៅដ្ឋាន[1]]**

**សេចក្តីជូនដំណឹងស្តីពីសិទ្ធិកាន់កាប់ជាកម្មសិទ្ធិដែលស្ថិតក្រោមច្បាប់ស្តីពីអំពើហិង្សាប្រឆាំងនឹងស្ត្រី[2]**

## ជូនចំពោះអ្នកជួលលំនៅដ្ឋាន និងបេក្ខជនដាក់ពាក្យសុំទាំងអស់

ច្បាប់ស្តីពីអំពើហិង្សាប្រឆាំងនឹងស្ត្រី (VAWA) ផ្តល់ជូនការការពារដល់ជនរងគ្រោះនៃអំពើហិង្សាក្នុងគ្រួសារ អំពើហិង្សានៃការណាត់ជួប បុរសនិងស្ត្រី ការរំលោភផ្លូវភេទ ឬការឈ្លបចាប់។ ការការពារដោយច្បាប់ VAWA ដែលអាចប្រើបានមិនមែនតែចំពោះស្ត្រីប៉ុណ្ណោះទេ ប៉ុន្តែអាចប្រើបានស្មើភាពគ្នាចំពោះបុគ្គលទាំងអស់ ដោយមិនគិតពីភេទ អត្តសញ្ញាណយ៉េនឌ័រ ឬទំនោរការរួមភេទ។[3] ក្រសួងអភិវឌ្ឍន៍លំនៅដ្ឋាន និងទីក្រុងសហរដ្ឋអាមេរិក (HUD) គឺជាភ្នាក់ងារសហព័ន្ធដែលត្រួតពិនិត្យថា **[បញ្ចូលឈ្មោះកម្មវិធី ឬជំនួយការជួលលំនៅដ្ឋាន]** ស្របតាមច្បាប់ VAWA ។ សេចក្តីជូនដំណឹងនេះ ពន្យល់អំពីសិទ្ធិរបស់អ្នកដែលស្ថិតក្រោមច្បាប់ VAWA ។ សំណុំបែបបទស្តីពីការបញ្ជាក់ដែលបានអនុម័តតាម HUD ត្រូវបានភ្ជាប់ទៅនឹងសេចក្តីជូនដំណឹងនេះ។ អ្នកអាចបំពេញសំណុំបែបបទនេះ ដើម្បី បង្ហាញថាអ្នកមានអំពើហិង្សាក្នុងគ្រួសារ ឬជាជនរងគ្រោះនៃអំពើហិង្សាក្នុងគ្រួសារ អំពើហិង្សានៃការណាត់ជួបបុរសនិងស្ត្រី ការរំលោភផ្លូវភេទ ឬការឈ្លបចាប់ ហើយអ្នកមានបំណងចង់ប្រើសិទ្ធិរបស់អ្នកដែលស្ថិតក្រោមច្បាប់ VAWA"។

## ការការពារសម្រាប់អ្នកជួលលំនៅដ្ឋាន

តាមរបៀបផ្សេងទៀត ប្រសិនបើអ្នកមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ចំពោះជំនួយដែលស្ថិតក្រោម **[ឈ្មោះបញ្ចូលឈ្មោះកម្មវិធី ឬជំនួយជួលលំនៅដ្ឋាន]**, អ្នកមិនអាចត្រូវបានបដិសេធចំពោះការទទួលស្គាល់ ឬបដិសេធជំនួយ ដោយសារតែអ្នកមានអំពើហិង្សាក្នុងគ្រួសារ ឬជាជនរងគ្រោះនៃអំពើហិង្សាក្នុងគ្រួសារ អំពើហិង្សានៃការណាត់ជួបបុរសនិងស្ត្រី ការរំលោភផ្លូវភេទ ឬការឈ្លបចាប់។

## ការការពារសម្រាប់អ្នកជួលលំនៅដ្ឋាន

ប្រសិនបើអ្នកនឹងទទួលបានជំនួយដែលស្ថិតក្រោម **[ឈ្មោះបញ្ចូលឈ្មោះកម្មវិធី ឬជំនួយជួលលំនៅដ្ឋាន]**, អ្នកអាចមិនត្រូវបាន បដិសេធជំនួយ ត្រូវបញ្ឈប់ពីការចូលរួម ឬត្រូវបណ្តេញចេញពីលំនៅដ្ឋានជួលរបស់អ្នក ដោយសារតែអ្នកមានអំពើហិង្សាក្នុងគ្រួសារ ឬជាជនរងគ្រោះនៃអំពើហិង្សាក្នុងគ្រួសារ អំពើហិង្សានៃការណាត់ជួបបុរសនិងស្ត្រី ការរំលោភផ្លូវភេទ ឬការឈ្លបចាប់។

---

[1] សេចក្តីជូនដំណឹងនេះ ប្រើក្រុមហ៊ុនផ្តល់សេវាកម្មលំនៅដ្ឋាន HP សម្រាប់អ្នកផ្តល់សេវាកម្មលំនៅដ្ឋាន ប៉ុន្តែអ្នកផ្តល់សេវាកម្មលំនៅដ្ឋានត្រូវ បញ្ចូលឈ្មោះរបស់ខ្លួនជាកន្លែងដែលក្រុមហ៊ុនផ្តល់សេវាកម្មលំនៅដ្ឋាន HP ត្រូវប្រើប្រាស់។ បទប្បញ្ញត្តិជាក់លាក់នៃកម្មវិធីអភិវឌ្ឍលំនៅដ្ឋាន និង
ទីក្រុង HUD កំណត់អត្តសញ្ញាណរបស់បុគ្គល ឬអង្គភាពដែលទទួលខុសត្រូវចំពោះការផ្តល់សេចក្តីជូនដំណឹងស្តីពីសិទ្ធិកាន់កាប់ជាកម្មសិទ្ធិ។

[2] ទោះបីជាមានឈ្មោះច្បាប់នេះក៏ដោយ ក៏ការការពារដោយច្បាប់ VAWA អាចប្រើបានដោយមិនគិតពីភេទ អត្តសញ្ញាណយេនឌ័រ ឬទំនោរផ្លូវភេទឡើយ។

[3] អ្នកផ្តល់សេវាកម្មលំនៅដ្ឋានមិនអាចរើសអើងដោយផ្អែកលើលើមូលដ្ឋានចរិកលក្ខណៈដែលបានការពារណាមួយឡើយ ដែលរួមមានជាតិសាសន៍ ពណ៌សម្បុរ ប្រភពដើមជនជាតិ សាសនា ភេទ ស្ថានភាពគ្រួសារ និងពិការភាព ឬអាយុ។ លំនៅដ្ឋាន HUD-ជំនួយ និង HUD-ធានាត្រូវរៀបចំឡើង ដែលអាចរកបានសម្រាប់បុគ្គលមានសិទ្ធិស្របច្បាប់តាមបែបផ្សេងទាំងអស់ ដោយមិនគិតពីទំនោរផ្លូវភេទដែលឃ្លាំមើល ឬជាក់ស្តែង អត្តសញ្ញាណយ៉េនឌ័រ ឬមានគ្រួសារឬអត់។

ដូចគ្នានេះផងដែរ ប្រសិនបើអ្នក ឬបុគ្គលដែលមានសម្ព័ន្ធភាពរបស់អ្នក ឬជាជនរងគ្រោះនៃអំពើហិង្សាក្នុងគ្រួសារ អំពើហិង្សានៃ ការណាត់ជួបបុរសនិងស្ត្រី ការរំលោភផ្លូវភេទ ឬការឈ្លបចាប់ ដោយសមាជិកម្នាក់នៃក្រុមគ្រួសាររបស់អ្នក ឬភ្ញៀវណាម្នាក់នោះ អ្នកមិនអាចត្រូវបានបដិសេធជំនួយជួលលំនៅដ្ឋាន ឬសិទ្ធិកាន់កាប់ដែលស្ថិតក្រោម **[ឈ្មោះបញ្ចូលឈ្មោះកម្មវិធី ឬជំនួយជួលលំនៅដ្ឋាន]** តែមួយគត់ចំពោះមូលដ្ឋាននៃសកម្មភាពឧក្រិដ្ឋកម្មដោយផ្ទាល់ ដែលពាក់ព័ន្ធនឹងអំពើហិង្សាក្នុងគ្រួសារ អំពើហិង្សានៃការណាត់ជួបបុរសនិងស្ត្រី ការរំលោភផ្លូវភេទ ឬការឈ្លបចាប់។

បុគ្គលដែលមានសម្ព័ន្ធភាព មានន័យថា ប្ដីប្រពន្ធ ឪពុកម្ដាយ បងប្អូនប្រុស បងប្អូនស្រី ឬកូនរបស់អ្នក ឬបុគ្គលដែលក្នុងនោះអ្នកដែលស្ថិតនៅកន្លែងរបស់មាតាបិតា ឬអាណាព្យាបាល (ឧទាហរណ៍បុគ្គលពាក់ព័ន្ធ គឺស្ថិតនៅក្នុងការថែទាំ សិទ្ធិធ្វើជាអាណាព្យាបាល ឬការគ្រប់គ្រងរបស់អ្នក); ឬបុគ្គល  អ្នកជួលលំនៅដ្ឋាន ឬអ្នកកាន់កាប់លំនៅដ្ឋានណាម្នាក់ ដែលរស់នៅក្នុងគ្រួសាររបស់អ្នក។

**ការយកចេញជនរំលោភបំពាន ឬឧក្រិដ្ឋជនពីគ្រួសារ**

ក្រុមហ៊ុនផ្ដល់សេវាកម្មលំនៅដ្ឋាន HP អាចបែងចែក (ជាពីរចំណែក) កិច្ចសន្យាជួលលំនៅដ្ឋានរបស់អ្នក ជាគោលបំណងដើម្បី បណ្ដេញបុគ្គល ឬបញ្ចប់ជំនួយបុគ្គលដែលបានចូលរួមក្នុងសកម្មភាពឧក្រិដ្ឋ (ជនរំលោភបំពាន ឬឧក្រិដ្ឋជន) ដោយផ្ទាល់ ដែល ទាក់ទងទៅនឹងអំពើហិង្សាក្នុងគ្រួសារ អំពើហិង្សានៃការណាត់ជួបបុរសនិងស្ត្រី ការរំលោភផ្លូវភេទ ឬការឈ្លបចាប់។ ។

ប្រសិនបើក្រុមហ៊ុនផ្ដល់សេវាកម្មលំនៅដ្ឋាន HP ជ្រើសរើសយកចេញជនរំលោភបំពាន ឬឧក្រិដ្ឋជន ក្រុមហ៊ុនផ្ដល់សេវាកម្មលំនៅដ្ឋាន HP អាចមិនដកយកសិទ្ធិរបស់អ្នកជួលលំនៅដ្ឋានស្របច្បាប់ បើមិនដូច្នេះទេ ដាក់ទោសអ្នកជួលលំនៅដ្ឋានដែលនៅសល់។  ប្រសិន បើជនរំលោភបំពាន ឬឧក្រិដ្ឋជនដែលបណ្ដេញចេញ គឺជាអ្នកជួលលំនៅដ្ឋានតែម្នាក់ ដើម្បីបង្កើតឡើងភាពមានសិទ្ធិស្របច្បាប់ចំពោះជំនួយដែលស្ថិតក្រោមកម្មវិធីនេះ ក្រុមហ៊ុនផ្ដល់សេវាកម្មលំនៅដ្ឋាន HP ត្រូវតែអនុញ្ញាតឱ្យអ្នកជួលលំនៅដ្ឋានដែលជាជនរងគ្រោះ និង សមាជិកគ្រួសារផ្សេងទៀត ដើម្បីស្ថិតនៅក្នុងលំនៅដ្ឋានមួយរយៈពេល  ក្នុងគោលបំណងដើម្បីបង្កើតភាពមានសិទ្ធិស្របច្បាប់ ដែលស្ថិតក្រោមកម្មវិធីនេះ ឬស្ថិតនៅក្រោមកម្មវិធីលំនៅដ្ឋាន HUD មួយផ្សេងទៀត ដែលគ្រប់គ្រងដោយច្បាប់ VAWA ឬស្វែងរក លំនៅដ្ឋានជំនួស។

ការយកចេញជនរំលោភបំពាន ឬឧក្រិដ្ឋជនពីគ្រួសារនោះ ក្រុមហ៊ុនផ្ដល់សេវាកម្មលំនៅដ្ឋាន HP ត្រូវតែអនុវត្តតាមនីតិវិធីស្ដីពី ការបណ្ដេញចេញនៅថ្នាក់សហព័ន្ធ រដ្ឋ និងមូលដ្ឋាន។  ដើម្បីបែងចែកកិច្ចសន្យាជួលលំនៅដ្ឋាន ក្រុមហ៊ុនផ្ដល់សេវាកម្មលំនៅដ្ឋាន HP អាចស្នើសុំអ្នកដើម្បីផ្ដល់ជូនឯកសារ ប៉ុន្តែមិនត្រូវបានទាមទារឡើយចំពោះឯកសារ ឬលិខិតបញ្ជាក់ឧបទ្ទវហេតុនៃអំពើហិង្សាក្នុងគ្រួសារ អំពើហិង្សានៃការណាត់ជួបបុរសនិងស្ត្រី ការរំលោភផ្លូវភេទ ឬការឈ្លបចាប់។

**ការផ្លាស់ប្ដូរទៅលំនៅដ្ឋានមួយទៀត**

តាមការស្នើសុំរបស់អ្នក ក្រុមហ៊ុនផ្ដល់សេវាកម្មលំនៅដ្ឋាន HP អាចអនុញ្ញាតឱ្យអ្នកដើម្បីផ្លាស់ប្ដូរទៅលំនៅដ្ឋានផ្សេងទៀត ដែល អាស្រ័យលើភាពអាចប្រព្រឹត្តទៅបានចំពោះលំនៅដ្ឋានផ្សេងទៀត និងនៅតែរក្សាការផ្ដល់ជំនួយរបស់អ្នក។  ដើម្បីអនុម័តតាមការស្នើសុំ ក្រុមហ៊ុនផ្ដល់សេវាកម្មលំនៅដ្ឋាន HP អាចស្នើសុំអ្នកដើម្បីផ្ដល់ជូនឯកសារ ប៉ុន្តែមិនត្រូវបាន

ទាមទារឡើយចំពោះឯកសារ ឬលិខិត បញ្ជាក់ឧបទ្ទវហេតុនៃអំពើហិង្សាក្នុងគ្រួសារ អំពើហិង្សានៃការណាត់ជួបបុរសនិងស្ត្រី ការរំលោភផ្លូវភេទ ឬការឈ្លបចាប់។ ប្រសិនបើការស្នើរសុំនេះ គឺជាសំណើសុំការផ្លាស់ប្តូរទីកន្លែងសម្រាប់ការសង្គ្រោះបន្ទាន់នោះ អ្នកផ្តល់សេវាកម្មលំនៅដ្ឋាន អាចស្នើសុំអ្នកឱ្យដាក់សំណើជាលាយលក្ខណ៍អក្សរ ឬបំពេញសំណុំបែបបទជាទីកន្លែងដែលអ្នកបញ្ជាក់ថា អ្នកបំពេញតាមលក្ខណៈវិនិច្ឆ័យការផ្លាស់ប្តូរទីកន្លែងសម្រាប់ការសង្គ្រោះបន្ទាន់ ដែលស្ថិតក្រោមច្បាប់ VAWA។ លក្ខណៈវិនិច្ឆ័យគឺ៖

**(1) អ្នកជាជនរងគ្រោះនៃអំពើហិង្សាក្នុងគ្រួសារ អំពើហិង្សានៃការណាត់ជួបបុរសនិងស្ត្រី ការរំលោភផ្លូវភេទ ឬការឈ្លបចាប់។** ប្រសិនបើអ្នកផ្តល់សេវាកម្មលំនៅដ្ឋានរបស់អ្នក មិនមានឯកសារដែលបញ្ជាក់ថា អ្នកជាជនរងគ្រោះនៃអំពើហិង្សាក្នុងគ្រួសារ អំពើហិង្សានៃការណាត់ជួបបុរសនិងស្ត្រី ការរំលោភផ្លូវភេទ ឬការឈ្លបចាប់នោះទេ អ្នកផ្តល់សេវាកម្មលំនៅដ្ឋានរបស់អ្នកអាចស្នើសុំអ្នកនូវឯកសារបែបនេះ ដូចដែលបានរៀបរាប់ក្នុងផ្នែកឯកសារខាងក្រោម។

**(2) អ្នកស្នើសុំយ៉ាងច្បាស់លាស់ចំពោះការផ្លាស់ប្តូរទីកន្លែងសម្រាប់ការសង្គ្រោះបន្ទាន់។** អ្នកផ្តល់សេវាកម្មលំនៅដ្ឋានរបស់អ្នក អាចជ្រើសរើសដើម្បីទាមទារថាអ្នកត្រូវដាក់ជូនសំណុំបែបបទឬអាចទទួលយកសំណើជាលាយលក្ខណ៍អក្សរ ឬផ្ទាល់មាត់។

**(3) អ្នកមានជំនឿសមហេតុផលថា មានការគំរាមនៅពេលខ្លីខាងមុខ កើតឡើងដោយសារអំពើឃោរឃៅ បើអ្នកស្ថិតនៅក្នុងផ្ទះបច្ចុប្បន្នរបស់អ្នក។**

ហើយនេះមានន័យថា អ្នកមានមូលហេតុភ័យខ្លាចថាប្រសិនបើអ្នកមិនទទួលបានការផ្លាស់ប្តូរទីកន្លែងនោះទេ អ្នកអាចនឹងទទួលរងអំពើហិង្សានាពេលដ៏ខ្លី។

ឬ

**អ្នកគឺជាជនរងគ្រោះនៃការរំលោភផ្លូវភេទ និងការវាយ ដែលបានកើតឡើងនៅលើបរិវេណលំនៅដ្ឋានក្នុងរយៈពេល 90 ថ្ងៃនៃថ្ងៃប្រតិទិន មុនពេលអ្នកស្នើសុំការផ្លាស់ប្តូរទីកន្លែង។** ប្រសិនបើអ្នកជាជនរងគ្រោះនៃការរំលោភផ្លូវភេទ បន្ទាប់មកដោយ មានលក្ខណៈសម្បត្តិគ្រប់គ្រាន់បន្ថែមទៀតចំពោះការផ្លាស់ប្តូរទីកន្លែងសម្រាប់ការសង្គ្រោះបន្ទាន់ ដោយសារតែអ្នកជឿជាក់ដោយសមហេតុផលថា អ្នកត្រូវបានគំរាមកំហែងចំពោះធ្វើឱ្យមានគ្រោះថ្នាក់ដែលជិតកើតមានឡើងពីអំពើហិង្សាតទៅទៀត ប្រសិន បើអ្នកនៅតែស្ថិតនៅក្នុងលំនៅដ្ឋានរបស់អ្នកនោះ អ្នកអាចមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ចំពោះការផ្លាស់ប្តូរទីកន្លែងសម្រាប់ការសង្គ្រោះបន្ទាន់ ប្រសិនបើការរំលោភផ្លូវភេទកើតមានឡើងបាន នៅលើបរិវេណកម្មសិទ្ធិ ដែលក្នុងនោះអ្នកកំពុងស្វែងរកការផ្លាស់ប្តូរទីកន្លែង ហើយថាការវាយបានកើតឡើងក្នុងរយៈពេល 90 ថ្ងៃនៃថ្ងៃប្រតិទិន មុនពេលអ្នកស្នើសុំច្បាស់លាស់ ចំពោះ ការផ្លាស់ប្តូរទីកន្លែង។

ក្រុមហ៊ុនផ្តល់សេវាកម្មលំនៅដ្ឋាន HP នឹងរក្សាការសម្ងាត់ការផ្លាស់ប្តូរទីកន្លែងសម្រាប់ការសង្គ្រោះបន្ទាន់ សម្រាប់ជនរងគ្រោះនៃអំពើហិង្សាក្នុងគ្រួសារ អំពើហិង្សានៃការណាត់ជួបបុរសនិងស្ត្រី ការរំលោភផ្លូវភេទ ឬការឈ្លបចាប់ នឹងទីតាំងនៃការផ្លាស់ប្តូរទីកន្លែងណាមួយដោយជនរងគ្រោះនានា នឹងគ្រួសាររបស់ពួកគេ។

ផែនការផ្លាស់ប្តូរទីកន្លែងសម្រាប់ការសង្គ្រោះបន្ទាន់របស់ក្រុមហ៊ុនផ្តល់សេវាកម្មលំនៅដ្ឋាន HP ផ្តល់ព័ត៌មានបន្ថែមទៀតអំពីការផ្លាស់ប្តូរ ទីកន្លែងសម្រាប់ការសង្គ្រោះបន្ទាន់ ហើយក្រុមហ៊ុនផ្តល់សេវាកម្មលំនៅដ្ឋាន HP ត្រូវថតចម្លងផែនការផ្លាស់ប្តូរទីកន្លែងសម្រាប់ ការសង្គ្រោះបន្ទាន់ ដែលអាចមានសម្រាប់អ្នក បើអ្នកស្នើសុំពិនិត្យមើលវា។

**ការចងក្រងឯកសារថាអ្នកជាជនរងគ្រោះ ឬ អ្នកជាជនរងគ្រោះនៃអំពើហិង្សាក្នុងគ្រួសារ អំពើហិង្សានៃការណាត់ជួបបុរសនិងស្ត្រី ការរំលោភផ្លូវភេទ ឬការឈ្លបចាប់**

ក្រុមហ៊ុនផ្តល់សេវាកម្មលំនៅដ្ឋាន HP អាចស្នើសុំអ្នកដើម្បីផ្តល់ជូនឯកសារ ប៉ុន្តែមិនត្រូវបានទាមទារឡើយចំពោះឯកសារ "បញ្ជាក់" ថាអ្នកជាជនរងគ្រោះ ឬ អ្នកជាជនរងគ្រោះនៃអំពើហិង្សាក្នុងគ្រួសារ អំពើហិង្សានៃការណាត់ជួបបុរសនិងស្ត្រី ការរំលោភផ្លូវភេទ ឬការ ឈ្លបចាប់។ សំណើបែបនេះពីក្រុមហ៊ុនផ្តល់សេវាកម្មលំនៅដ្ឋាន HP ត្រូវសរសេរជាលាយលក្ខណ៍អក្សរ និងក្រុមហ៊ុនផ្តល់សេវាកម្មលំនៅដ្ឋាន HP ត្រូវតែផ្តល់ជូនអ្នកយ៉ាងហោចណាស់រយៈពេល 14 ថ្ងៃនៃថ្ងៃធ្វើការ (ថ្ងៃសៅរ៍ អាទិត្យ និងថ្ងៃឈប់សម្រាកសហព័ន្ធ មិនត្រូវបានរាប់បញ្ចូល) ពីថ្ងៃដែលអ្នកទទួលបានកាការស្នើសុំផ្តល់ឯកសារ។ ក្រុមហ៊ុនផ្តល់សេវាកម្មលំនៅដ្ឋាន HP អាចពន្យាពេល ថ្ងៃផុតកំណត់ការដាក់ជូនឯកសារតាមការស្នើសុំរបស់អ្នក ប៉ុន្តែមិនត្រូវទាមទារឡើយ។

អ្នកអាចផ្តល់ជូនឯកសារមួយច្បាប់ដូចខាងក្រោម ជូនទៅក្រុមហ៊ុនផ្តល់សេវាកម្មលំនៅដ្ឋាន HP ទុកជាឯកសារ។ វាជាជម្រើសរបស់ អ្នកថា ឯកសារណាមួយខាងក្រោម ដើម្បីដាក់ជូន ប្រសិនបើក្រុមហ៊ុនផ្តល់សេវាកម្មលំនៅដ្ឋាន HP ស្នើសុំអ្នកឱ្យផ្តល់ជូនឯកសារ ដែលអ្នកជាជនរងគ្រោះ ឬ អ្នកជាជនរងគ្រោះនៃអំពើហិង្សាក្នុងគ្រួសារ អំពើហិង្សានៃការណាត់ជួបបុរសនិងស្ត្រី ការរំលោភផ្លូវភេទ ឬការឈ្លបចាប់។

- សំណុំបែបបទអំពីការបញ្ជាក់អនុម័ត HUD ដែលបានបញ្ចប់ ផ្តល់ជូនអ្នកដោយក្រុមហ៊ុនផ្តល់សេវាកម្មលំនៅដ្ឋាន HP ដោយមានការជូនដំណឹងនេះ ដែលផ្តល់ឯកសារឧប្បត្តិហេតុនៃអំពើហិង្សាក្នុងគ្រួសារ អំពើហិង្សានៃការណាត់ជួបបុរសនិងស្ត្រី ការរំលោភផ្លូវភេទ ឬការឈ្លបចាប់។ សំណុំបែបបទនឹងសាកសួរឈ្មោះរបស់អ្នក កាលបរិច្ឆេទ ម៉ោង និងទីកន្លែងឧបទ្ទវហេតុនៃអំពើហិង្សាក្នុងគ្រួសារ អំពើហិង្សានៃការណាត់ជួបបុរសនិងស្ត្រី ការរំលោភផ្លូវភេទ ឬការឈ្លបចាប់ និងការពណ៌នាអំពីឧប្បត្តិហេតុនេះ។ សំណុំបែបបទបញ្ជាក់នេះ ដែលផ្តល់ជូននោះ រួមបញ្ចូលទាំងឈ្មោះជនរំលោភបំពាន ឬឧក្រិដ្ឋជន ប្រសិនបើអ្នកបំពានឈ្មោះរបស់ជនរំលោភបំពាន ឬឧក្រិដ្ឋជនត្រូវបានគេស្គាល់ ហើយមានសុវត្ថិភាពដើម្បី ផ្តល់ជូន។
- កំណត់ត្រារបស់ទីភ្នាក់ងារអនុវត្តច្បាប់សហព័ន្ធ រដ្ឋ កុលសម្ព័ន្ធ ដែនដីអាណាខេត្ត ឬមូលដ្ឋាន តុលាការ ឬទីភ្នាក់ងាររដ្ឋបាល ដែលផ្តល់ឯកសារឧប្បត្តិហេតុនៃអំពើហិង្សាក្នុងគ្រួសារ អំពើហិង្សានៃការណាត់ជួបបុរសនិងស្ត្រី ការរំលោភផ្លូវភេទ ឬការឈ្លបចាប់។ ឧទាហរណ៍កំណត់ត្រាបែបនេះ រួមបញ្ចូលទាំងសេចក្តីរាយការណ៍របស់ប៉ូលិស ការបង្គាប់បញ្ជាដែលការពារ និងការបង្គាប់បញ្ជាទប់ស្កាត់ក្នុងចំណោមអ្នកដទៃទៀត។
- របាយការណ៍ដែលអ្នកត្រូវចុះហត្ថលេខាដោយមានហត្ថលេខារបស់និយោជិត ភ្នាក់ងារ ឬអ្នកស្ម័គ្រចិត្តនៃអ្នកផ្តល់សេវាកម្មជាជនរងគ្រោះ មេធាវី អ្នកជំនាញវិជ្ជាជីវៈវេជ្ជសាស្ត្រ ឬអ្នកជំនាញវិជ្ជាជីវៈខាងសុខភាពផ្លូវចិត្ត (ដោយរួមគ្នា, "ដែលមានជំនាញវិជ្ជាជីវៈ") ពីអ្នកទាំងនោះ ដែលអ្នកបានស្វែងរកជំនួយក្នុងការដោះស្រាយ អំពើហិង្សាក្នុងគ្រួសារ អំពើហិង្សានៃការណាត់ជួបបុរសនិងស្ត្រី ការរំលោភផ្លូវភេទ ឬការឈ្លបចាប់ ឬផលប៉ះពាល់នៃការរំលោភបំពាន និងដោយអ្នកជំនាញវិជ្ជាជីវៈបានជ្រើសរើសដោយអ្នក ដែលបង្ហាញក្រោមការដាក់ពិន័យសម្បថ ដែលគាត់ឬនាងជឿជាក់ថា ឧបទ្ទវហេតុនេះ ឬឧបទ្ទវហេតុនានានៃអំពើហិង្សាក្នុងគ្រួសារ អំពើហិង្សានៃការណាត់ជួបបុរសនិងស្ត្រី ការរំលោភផ្លូវភេទ ឬការឈ្លបចាប់ គឺជាមូលដ្ឋានសម្រាប់ការការពារ។

- របាយការណ៍ ឬភស្តុតាងណាមួយផ្សេងទៀត ដែលក្រុមហ៊ុនផ្តល់សេវាកម្មលំនៅដ្ឋាន HP បានយល់ព្រមទទួលយក។

ប្រសិនបើអ្នកខកខាន ឬបដិសេធមិនផ្តល់ឯកសារទាំងនេះក្នុងរយៈពេល 14 ថ្ងៃនៃថ្ងៃធ្វើការនោះទេ ក្រុមហ៊ុនផ្តល់សេវាកម្មលំនៅដ្ឋាន HP មិនត្រូវផ្តល់ជូនអ្នកនូវការការពារដែលមាននៅក្នុងសេចក្តីជូនដំណឹងនេះឡើយ។ ប្រសិនបើទទួលបានភស្តុតាងមានជម្លោះ ដែលឧបទ្ទវហេតុនៃអំពើហិង្សាក្នុងគ្រួសារ អំពើហិង្សានៃការណាត់ជួបបុរសនិងស្ត្រី ការរំលោភផ្លូវភេទ ឬការលួចតាមដាន ដែលបានប្រព្រឹត្ត (ដូចជាសំណុំបែបបទបញ្ជាក់ពីសមាជិកពីរនាក់ ឬច្រើននាក់នៃគ្រួសារមួយគ្នា ដែលមានការបញ្ជាក់អះអាងនីមួយៗ ថាជាជនរងគ្រោះ ហើយដែលដាក់ឈ្មោះសមាជិកក្នុងគ្រួសារដែលប្តឹងទាមទារចំនួនម្នាក់ ឬច្រើននាក់ផ្សេងទៀត ថាជាជនរំលោភបំពាន ឬឧក្រិដ្ឋជន) នោះ ក្រុមហ៊ុនផ្តល់សេវាកម្មលំនៅដ្ឋាន HP មានសិទ្ធិស្នើសុំឱ្យអ្នកផ្តល់ជូន ឯកសាររបស់ភាគីទីបីក្នុងរយៈពេលសាមសិប 30 ថ្ងៃក្នុងគោលបំណងដើម្បីដោះស្រាយជម្លោះនេះ។ ប្រសិនបើអ្នកខកខាន ឬបដិសេធមិនផ្តល់ឯកសាររបស់ភាគីទីបី ដែលមានភស្តុតាងមិនស្របគ្នានោះ ក្រុមហ៊ុនផ្តល់សេវាកម្មលំនៅដ្ឋាន HP មិនត្រូវផ្តល់ជូនអ្នកនូវការការពារ ដែលមាននៅក្នុងសេចក្តីជូនដំណឹងនេះឡើយ។

**ការថែរក្សារឿងសម្ងាត់**

ក្រុមហ៊ុនផ្តល់សេវាកម្មលំនៅដ្ឋាន HP ត្រូវតែរក្សាព័ត៌មានសម្ងាត់ណាមួយដែលអ្នកផ្តល់ជូន ដែលទាក់ទងទៅនឹងការអនុវត្តសិទ្ធិ របស់អ្នកដែលស្ថិតក្រោមច្បាប់ VAWA ដែលរួមមានទាំងហេតុការណ៍អ្នកនឹងអនុវត្តសិទ្ធិរបស់អ្នក ដែលស្ថិតក្រោមច្បាប់ VAWA។

ក្រុមហ៊ុនផ្តល់សេវាកម្មលំនៅដ្ឋាន HP មិនត្រូវអនុញ្ញាតឱ្យមានជំនួយដែលគ្រប់គ្រងដោយបុគ្គលណាម្នាក់ ឬសេវាកម្មផ្សេងទៀត ក្នុងនាមជាក្រុមហ៊ុនផ្តល់សេវាកម្មលំនៅដ្ឋាន HP ឡើយ (ឧទាហរណ៍និយោជិត និងបុគ្គលិកម៉ៅការ) ដើម្បីមានសិទ្ធិប្រើព័ត៌មាន សម្ងាត់នោះ លុះត្រាតែមានហេតុផលដែលទាមទារយ៉ាងពិសេសសម្រាប់បុគ្គលទាំងនេះ ដើម្បីមានសិទ្ធិប្រើព័ត៌មាននេះ ដែលស្ថិតក្រោមច្បាប់សហព័ន្ធ រដ្ឋ ឬមូលដ្ឋានដែលត្រូវអនុវត្ត។

ក្រុមហ៊ុនផ្តល់សេវាកម្មលំនៅដ្ឋាន HP មិនត្រូវបញ្ចូលព័ត៌មានរបស់អ្នកទៅក្នុងមូលដ្ឋានទិន្នន័យដែលបានចែករំលែកណាមួយ ឬបញ្ចេញឱ្យដឹងព័ត៌មានរបស់អ្នកទៅអង្គភាពផ្សេងទៀត ឬបុគ្គលណាម្នាក់ឡើយ។ ទោះជាយ៉ាងណាក៏ដោយ ក៏ក្រុមហ៊ុនផ្តល់សេវាកម្មលំនៅដ្ឋាន HP អាចបញ្ចេញឱ្យដឹងព័ត៌មាន ប្រសិនបើៈ

- អ្នកផ្តល់ការអនុញ្ញាតជាលាយលក្ខណ៍អក្សរជូនដល់ក្រុមហ៊ុនផ្តល់សេវាកម្មលំនៅដ្ឋាន HP ដើម្បីបញ្ចេញឱ្យដឹងព័ត៌មាន តាមពេលវេលាកំណត់។
- ក្រុមហ៊ុនផ្តល់សេវាកម្មលំនៅដ្ឋាន HP ត្រូវការប្រើព័ត៌មាននៅក្នុងនីតិវិធីស្តីពីការបណ្តេញចេញ ឬការបញ្ឈប់ដូចជា ដើម្បីបណ្តេញចេញជនរំលោភបំពាន ឬឧក្រិដ្ឋជនរបស់អ្នក ឬបញ្ឈប់ជនរំលោភបំពាន ឬឧក្រិដ្ឋជនពីជំនួយក្រោម កម្មវិធីនេះ។
- ច្បាប់តម្រូវឱ្យក្រុមហ៊ុនផ្តល់សេវាកម្មលំនៅដ្ឋាន HP ឬម្ចាស់លំនៅដ្ឋានជួលរបស់អ្នក ដើម្បីបញ្ចេញឱ្យដឹងព័ត៌មាន។

ច្បាប់ VAWA មិនកំណត់កាតព្វកិច្ចក្រុមហ៊ុនផ្តល់សេវាកម្មលំនៅដ្ឋាន HP ដើម្បីទទួលយកការចេញបញ្ជាតុលាការអំពីការចូលប្រើ ឬគ្រប់គ្រងបរិវេណលំនៅដ្ឋានឡើយ។ ហើយនេះរួមបញ្ចូលទាំងការចេញបញ្ជានានា ដែលចេញជូនដើម្បីការពារជនរងគ្រោះ និង ការចេញបញ្ជាដែលបែងចែកបរិវេណលំនៅដ្ឋាន ក្នុងចំណោមសមាជិកគ្រួសារនៅក្នុងករណីដែលជាកន្លែងក្រុមគ្រួសារមួយបែកបាក់។

**ហេតុផលនានាដែលអ្នកជួលលំនៅដ្ឋានដែលមានសិទ្ធិស្របច្បាប់ចំពោះសិទ្ធិកាន់កាប់ ដែលស្ថិតក្រោមច្បាប់ VAWA អាចត្រូវបាន បណ្តេញចេញ ឬកម្មវិធីជំនួយអាចត្រូវបានបញ្ចប់**

អ្នកអាចត្រូវបានបណ្តេញចេញពីផ្ទះ និងការផ្តល់ជំនួយរបស់អ្នកអាចត្រូវបានបញ្ចប់ដោយសារការរំលោភបំពានកិច្ចសន្យាជួលធ្ងន់ធ្ងរ ឬម្តងហើយម្តងទៀត ដែលមិនទាក់ទងទៅនឹងអំពើហិង្សាក្នុងគ្រួសារ អំពើហិង្សានៃការណាត់ជួបបុរសនិងស្ត្រី ការរំលោភផ្លូវភេទ ឬការឈ្លបចាប់ ដែលបានប្រព្រឹត្តចំពោះអ្នក។ ទោះយ៉ាងណាក៏ដោយ ក៏ក្រុមហ៊ុនផ្តល់សេវាកម្មលំនៅដ្ឋាន HP មិនអាចមានអ្នកជួលលំនៅដ្ឋាននានា ដែលជាជនរងគ្រោះនៃអំពើហិង្សាក្នុងគ្រួសារ អំពើហិង្សានៃការណាត់ជួបបុរសនិងស្ត្រី ការរំលោភផ្លូវភេទ ឬការឈ្លបចាប់ ដែលមាន តម្រូវការទាមទារកំណត់វិធាននានាបន្ថែមទៀតជាងច្បាប់ដែលអនុវត្តចំពោះ អ្នកជួលលំនៅដ្ឋាននានា ដែលមិនមែនជាជនរងគ្រោះនៃអំពើហិង្សាក្នុងគ្រួសារ អំពើហិង្សានៃការណាត់ជួបបុរសនិងស្ត្រី ការរំលោភផ្លូវភេទ ឬការឈ្លបចាប់។
ការការពារដែលបានពណ៌នានៅក្នុងសេចក្តីជូនដំណឹងនេះអាចមិនអនុវត្ត ហើយអ្នកអាចនឹងត្រូវបណ្តេញចេញ ហើយជំនួយរបស់អ្នកត្រូវបញ្ចប់ បើក្រុមហ៊ុនផ្តល់សេវាកម្មលំនៅដ្ឋាន HP អាចបង្ហាញថាគ្មានការបណ្តេញអ្នក ឬការបញ្ចប់ជំនួយរបស់អ្នក នឹងបង្ហាញថាជា គ្រោះថ្នាក់ជាក់ស្តែងពិតប្រាកដដែលៈ

1) នឹងកើតមានឡើងនៅក្នុងពេលវេលាបន្ទាន់មួយ និង

2) អាចបណ្តាលឱ្យស្លាប់ ឬរបួសស្នាមរាងកាយធ្ងន់ធ្ងរដល់អ្នកជួលលំនៅដ្ឋានផ្សេងទៀត ឬអ្នកទាំងនោះ ដែលធ្វើការនៅលើបរិវេណលំនៅដ្ឋាន។

ប្រសិនបើក្រុមហ៊ុនផ្តល់សេវាកម្មលំនៅដ្ឋាន HP អាចបង្ហាញខាងលើនេះ ក្រុមហ៊ុនផ្តល់សេវាកម្មលំនៅដ្ឋាន HP ត្រូវបញ្ចប់ជំនួយ របស់អ្នកតែប៉ុណ្ណោះ ឬបណ្តេញអ្នក ប្រសិនបើគ្មានការចាត់វិធានការផ្សេងទៀត ដើម្បីកាត់បន្ថយ ឬលុបបំបាត់ការគំរាមកំហែងនេះ។

**ច្បាប់ផ្សេងទៀត**

ច្បាប់ VAWA មិនជំនួសឱ្យច្បាប់សហព័ន្ធ រដ្ឋ ឬមូលដ្ឋានដែលផ្តល់ជូនការការពារដល់ជនរងគ្រោះនៃអំពើហិង្សាក្នុងគ្រួសារ អំពើហិង្សា នៃការណាត់ជួបបុរសនិងស្ត្រី ការរំលោភផ្លូវភេទ ឬការឈ្លបចាប់។ អ្នកអាចត្រូវបានទទួលសិទ្ធិការពារលំនៅដ្ឋានបន្ថែមទៀតសម្រាប់ ជនរងគ្រោះនៃអំពើហិង្សាក្នុងគ្រួសារ អំពើហិង្សានៃការណាត់ជួបបុរសនិងស្ត្រី ការរំលោភផ្លូវភេទ ឬការឈ្លបចាប់ ដែលស្ថិតក្រោមច្បាប់សហព័ន្ធផ្សេងទៀត ព្រមទាំងក្រោមច្បាប់រដ្ឋ និងមូលដ្ឋានផងដែរ។

**គ្មានការអនុលោមទៅតាមតម្រូវការទាមទារចំពោះសេចក្តីជូនដំណឹងនេះ**

អ្នកអាចរាយការណ៍អំពីការរំលោភសិទ្ធិទាំងនេះពីអ្នកផ្តល់សេវាកម្មលំនៅដ្ឋានដែលបានធានា និងស្វែងរកជំនួយបន្ថែមទៀត ប្រសិនបើចាំបាច់ តាមរយៈការទាក់ទង ឬការដាក់ពាក្យបណ្តឹងដោយមាន **[បញ្ចូលព័ត៌មានទំនាក់ទំនងសម្រាប់អន្តរការីណាម្នាក់ បើអាចអនុវត្ត]** ឬ **[បញ្ចូលការិយាល័យនៅទីវាល HUD]** ។

**សម្រាប់ព័ត៌មានបន្ថែម**

អ្នកអាចពិនិត្យមើលច្បាប់ចម្លងនៃវិធាន VAWA ចុងក្រោយរបស់ HUD តាម **[បញ្ចូលតំណភ្ជាប់ការចុះបញ្ជីឈ្មោះសហព័ន្ធ]** ។ លើសពីនេះទៀតក្រុមហ៊ុនផ្តល់សេវាកម្មលំនៅដ្ឋាន HP ត្រូវថតចម្លងបទប្បញ្ញត្តិ VAWA របស់ HUD ដែលអាចមានសម្រាប់អ្នក បើអ្នកស្នើសុំពិនិត្យមើលបទប្បញ្ញត្តិ។

សម្រាប់សំណួរនានាដែលទាក់ទងនឹងច្បាប់ VAWA សូមទាក់ទង **[បញ្ចូលឈ្មោះកម្មវិធី ឬព័ត៌មានទំនាក់ទំនងជំនួយជួលលំនៅដ្ឋាន ដែលអាចឆ្លើយសំណួរនានាអំពីច្បាប់ VAWA]** ។

សម្រាប់ជំនួយដែលពាក់ព័ន្ធនឹងភាពទាក់ទងដែលរំលោភបំពាននោះ អ្នកអាចហៅទូរស័ព្ទតាមបណ្តាញទូរស័ព្ទទាន់ហេតុការណ៍

អំពើហិង្សាក្នុងគ្រួសារថ្នាក់ជាតិ តាមលេខ 1-800-799-7233 ឬសម្រាប់ប្រជាពលរដ្ឋដែលមានបញ្ហាស្តាប់ តាមលេខ 1-800-787-3224 (TTY) ។ អ្នកអាចទាក់ទង **[បញ្ចូលព័ត៌មានទំនាក់ទំនងសម្រាប់អង្គការមូលដ្ឋានដែលពាក់ព័ន្ធ]**។

ចំពោះអ្នកជួលលំនៅដ្ឋានដែលជាជនរងគ្រោះ ឬជាជនរងគ្រោះពីការឈ្លបចាប់ ដែលស្វែងរកជំនួយនោះ អាចមកជួបនៅមជ្ឈមណ្ឌលជាតិ សម្រាប់ជនរងគ្រោះនៃមជ្ឈមណ្ឌលធនធានការឈ្លបចាប់ដែលជាអំពើឧក្រិដ្ឋកម្ម តាមវែបសាយ https://www.victimsofcrime.org/our-programs/stalking-resource-center.

សម្រាប់ជំនួយដែលពាក់ព័ន្ធនឹងការរំលោភផ្លូវភេទ អ្នកអាចទាក់ទង **[បញ្ចូលព័ត៌មានទំនាក់ទំនងសម្រាប់អង្គការពាក់ព័ន្ធ]**

ជនរងគ្រោះពីការឈ្លបចាប់ ដែលស្វែងរកជំនួយ អាចទាក់ទង **[បញ្ចូលព័ត៌មានទំនាក់ទំនងសម្រាប់អង្គការពាក់ព័ន្ធ]**

**ឯកសារភ្ជាប់៖** សំណុំបែបបទបញ្ជាក់ HUD-5382 **[សំណុំបែបបទដែលបានអនុម័តសម្រាប់កម្មវិធីនេះ ត្រូវបានបញ្ចូល]**